**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន ហ្គ្រេនឌីស ធីមប៊ើរ អីលធីឌី
# និង
# ប្រតិភូបុគ្គលិក
# ក្រុមហ៊ុន ហ្គ្រេនឌីស ធីមប៊ើរ អីលធីឌី
# ស្ដីអំពីការព្យួរកិច្ចសន្យាការងារ

ឆ្នាំពីរពាន់ម្ភៃបីខែមករា ថ្ងៃទី០៦ វេលាម៉ោងដប់សាមសិបនាទីព្រឹក នៅក្រុមហ៊ុនហ្គ្រេនឌីស ធីមប៊ើរ អិលធីឌី មានកិច្ចប្រជុំរវាងតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក ប្រចាំក្រុមហ៊ុន ។

នៅក្នុងអង្គប្រជុំនេះ តំណាងក្រុមហ៊ុនបានធ្វើបច្ចុប្បន្នភាពអំពីស្ថានភាពរបស់ក្រុមហ៊ុនដែលនឹងកំពុងតែជួបប្រទះជូនដល់បុគ្គលិកទាំងអស់ថាលំហូរសាច់ប្រាក់និងការព្យាករណ៍ការចំណាយនានានៅតែជាបញ្ហាប្រឈមសម្រាប់ក្រុមហ៊ុនក្នុងស្ថានភាពបច្ចុប្បន្ន បើទោះជាស្ថានភាពការរីករាលដាលនៃជំងឺកូវីឌបានធូរស្រាលក៏ដោយ ក៏វិបត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅបន្តមានការលំបាក។ ដូច្នេះក្រុមហ៊ុនសម្រេចធ្វើការបន្តព្យួរកិច្ចសន្យាការងាររបស់បុគ្គលិកចំនួន១នាក់ ក្នុងរយៈពេល ០១ខែ ដោយគិតចាប់ពីថ្ងៃ ១៧ មករា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី ១៦ ខែ កុម្ភះ ឆ្នាំ២០២៣ ហើយចូលធ្វើការវិញនៅថ្ងៃទី ១៧ ខែកុម្ភះ ឆ្នាំ២០២៣ ។ ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្ដល់ប្រាក់ឧបត្ថម្ភជូន កម្មករនិយោជិតចំនួន ៣០% នៃប្រាក់ខែគោល (គិតជាដុល្លាអាមេរិក) ក្នុង១ខែសម្រាប់និយោជិត ដោយបើកមុនពេលព្យួរនិងបើកពីរដងក្នុងមួយខែ។

អង្គប្រជុំបានចប់វេលាម៉ោង ដប់មួយនាទីព្រឹក នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និង សហការគ្នាយ៉ាងរលូន ។ ដើម្បីបង្ហាញពីកិច្ចព្រមព្រៀងប្រជុំខាងលើ យើងខ្ញុំទាំងអស់គ្នាសូមផ្ដិតមេដៃ ធ្វើជាសាក្សី ។

ស្នាមមេដៃ

ប្រតិភូបុគ្គលិកពេញសិទ្ធិ ប្រត្តិភូជំនួយ

លោក ហែម ឈន លោក អ៊ុំ ពុទ្ធី

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២៣

**ហត្ថលេខាប្រធានប្រតិបត្តិ**

ហុង លីណា